# ការិយាល័យចៅហ្វាយក្រុងទទួលបន្ទុក ពលរដ្ឋវ័យចំណាស់


810 - 3rd Avenue, Suite 350
(អាគារកណ្តាល)
Seattle, WA  98104

ថ្ងៃ ច័ន្ទ ដល់ ថ្ងៃ សុក្រ
ម៉ោង 8:00 ព្រឹក ដល់ ម៉ោង 5:00 ល្ងាច

ទូរស័ព្ទ (206) 684-0500
ទូរសារ (206) 684-0494
TTY/TDD (206) 233-2778

គេហទំព័រ
www.seattle.gov/humanservices/mosc/


ការិយាល័យចៅហ្វាយក្រុងសម្រាប់ពលរដ្ឋវ័យចំណាស់ ដែលដឹកនាំ គ្រប់គ្រងដោយក្រសួងសេវាមនុស្សនៃទីក្រុង ស៊ីអ៊ែល អនុវត្តតាមច្បាប់នានាដែលមានប្រចាំតំបន់ រដ្ឋ និងសហព័ន្ធ ដែលហាមឃាត់នូវការប្រកាន់រើសអើង ។

កន្លែងស្នាក់នៅសម្រាប់មនុស្សដែលមាន ពិការភាព នឹងត្រូវបានផ្តល់ជូនរាល់ពេលណាដែលមានការស្នើសុំ ។

**Gregory J. Nickels**
ចៅហ្វាយក្រុងស៊ីអ៊ែល

**Irene Stewart**
នាយក ការិយាល័យចៅហ្វាយក្រុងសម្រាប់ពលរដ្ឋវ័យចំណាស់

# ការិយាល័យចៅហ្វាយក្រុង ទទួលបន្ទុក ពលរដ្ឋវ័យចំណាស់

## ជួយភាពក្លាយជាមនុស្សចាស់ដែលមានសុខភាពល្អ ការរស់នៅដោយខ្លួនឯង និង ការចូលរួមប្រឡូកក្នុងទីក្រុង និងសង្គម



ទីក្រុងស៊ីអ៊ែល
ក្រសួងសេវាមនុស្ស
**Gregory J. Nickels** ចៅហ្វាយក្រុង

Cambodian: Revised 05/01/2008



**ការិយាល័យចៅហ្វាយក្រុងខ្លួនឯងពលរដ្ឋវ័យចំណាស់** ជួយគាំទ្រដល់ភាពក្លាយជាមនុស្សចាស់ដែលប្រកបដោយសុខភាពល្អ ការរស់នៅប្រកបដោយឯករាជ្យភាព និង ការចូលរួមប្រឡូកជាមួយ ទីក្រុង និងសង្គម តាមរយៈការគ្រប់គ្រងត្រួតពិនិត្យលើការផ្តល់ជូន នូវជំនួយផ្នែកទឹកភ្លើង ការងារ និងកម្មវិធីសម្រាប់អ្នកស្ម័គ្រចិត្តផ្សេងៗ និងការភ្ជាប់ទំនាក់ទំនងរវាងមនុស្សចាស់ទាំងឡាយនិងក្រុមគ្រួសារ របស់គាត់ទៅនឹងធនធាននានារបស់សហគមន៍ដែលមានចម្រុះមួយចំនួនទៀត ។

## ព័ត៌មាន និងជំនួយសម្រាប់មនុស្សចាស់

ការិយាល័យចៅហ្វាយក្រុងទទួលបន្ទុកពលរដ្ឋវ័យចំណាស់ ផ្តល់ជូននូវសេវាផ្តល់ព័ត៌មានដែលមិនចាំបាច់មានការណាត់ជាមុន និងសេវាទូរស័ព្ទនៅកន្លែងតែមួយសម្រាប់មនុស្សវ័យចំណាស់នៅខោនធី ឃីង (King County) និងទីក្រុង ស៊ីអ៊ែល (Seattle) ព្រមទាំងសម្រាប់សមាជិកគ្រួសាររបស់គាត់ ។ យើងអាចបញ្ជូនលោកអ្នកទៅរក

ទីភ្នាក់ងារដែលសមស្របដើម្បីទទួលបាននូវការផ្តល់ការស្នាក់នៅ ការ-ថែទាំសុខភាព មធ្យោបាយធ្វើដំណើរ ចំណីអាហារ សិទ្ធិមនុស្សចាស់ ការថែទាំសម្រាប់រយៈពេលវែង សេវាកិច្ចការផ្ទះ សកម្មភាពផ្សេងៗ និងសេវាគ្រប់គ្រងលើករណីបែបបទនានា ។ ដើម្បីនិយាយជាមួយអ្នកផ្តល់ការគាំទ្រដល់មនុស្សចាស់ សូមទូរស័ព្ទទៅកាន់លេខ (206) 684-0500 ។

## មជ្ឈមណ្ឌលធនធានការងារសម្រាប់មនុស្សដែលមានអាយុ ចាប់ពី ៥៥ ឡើងទៅ

មជ្ឈមណ្ឌលធនធានការងារសម្រាប់មនុស្សដែលមានអាយុចាប់ពី៥៥ ឡើងទៅ ជួយអ្នកធ្វើការងារដែលមានវ័យចំណាស់ដើម្បីស្វែងរកការងារ ។ សេវាទាំងនេះមាន ផ្តល់ជូនដោយឥតគិតថ្លៃ ទាំងសម្រាប់ អ្នកស្វែងរកការងារ និងនិយោជក ។

ដើម្បីទទួលព័ត៌មាននេះ សូមទូរស័ព្ទទៅកាន់លេខ (206) 684-0500។

## មជ្ឈមណ្ឌលធនធានសម្រាប់អ្នកស្ម័គ្រចិត្ត

មានមធ្យោបាយជាច្រើនដើម្បីចូលរួមប្រឡូកក្នុងសហគមន៍របស់លោកអ្នក ។ មជ្ឈមណ្ឌលធនធានសម្រាប់អ្នកស្ម័គ្រចិត្តរបស់យើងអាចជួយលោកអ្នកក្នុងការស្វែងរកឱកាសសម្រាប់អ្នកស្ម័គ្រចិត្ត ឬព្រឹត្តិការណ៍ដែលស័ក្តិសមត្រូវនឹងលោកអ្នកបំផុត ។ ដើម្បីទទួលបានព័ត៌មាន សូមទូរស័ព្ទទៅកាន់លេខ (206) 684-0639 ។



## ថ្នាក់កុំព្យូទ័រសម្រាប់មនុស្សចាស់

វគ្គសិក្សាកុំព្យូទ័ររបស់យើង ផ្តល់ឱកាសសម្រាប់មនុស្សចាស់ (អាយុចាប់ពី 50 ឡើងទៅ )ដើម្បីឱ្យដឹងអំពីអត្ថប្រយោជន៍នៃការរៀនប្រើកុំព្យូទ័រ ។ គ្រូដឹកនាំរបស់យើងសុទ្ធតែជាអ្នកស្ម័គ្រចិត្តដែលមានការយល់ដឹងខាងផ្នែកកុំព្យូទ័រដែលមានអាយុច្រើនជាង ៥០ ឆ្នាំ ។
ដើម្បីចុះឈ្មោះចូលរៀនក្នុងវគ្គសិក្សានេះ សូមទូរស័ព្ទទៅកាន់លេខ (206) 684-0639 ។

## ការបញ្ចុះតម្លៃលើអត្រាទឹកភ្លើង



ក្រុមគ្រួសារដែលមានសិទ្ធិទទួលប្រាក់ចំណូលមនុស្សចាស់ (អាយុចាប់ពី 65 ឡើងទៅ) និងមនុស្សពេញវ័យដែលមានភាពពិការ អាចទទួលបានការបញ្ចុះតម្លៃ 50% លើវិក្កយបត្រភ្លើង (អគ្គីសនី) ពីភ្លើងទីក្រុង ស៊ីអ៊ែល និងទឹកភ្លើងសម្រាមសាធារណៈទីក្រុងស៊ីអ៊ែល (ទឹក លូបង្ហូរ សំណល់ និងសម្រាម)។
សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅលេខ (206) 684-0268 ។
ជំនួយក្នុងការបង់ប្រាក់បន្ទាន់ និងការប្រឹក្សាយោបល់សម្រាប់អតិថិជនដែលប្រើប្រាស់ទឹកភ្លើងនៅតាមលំនៅដ្ឋានដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលប្រឈមមុខនឹងការកាត់ផ្តាច់ ក៏អាចមានផងដែរ ។

## ហ្គោលខាដ (Gold Card) និង ហ្វ្លាសខាដ (FLASH Card)

ហ្គោលខាដសម្រាប់ភាពមានវ័យចំណាស់ដែលប្រកបដោយសុខភាពល្អ (Gold Card for Healthy Aging) ផ្តល់ជូនមនុស្សវ័យចំណាស់ដែល មានអាយុចាប់ពី 60 ឆ្នាំឡើងទៅ នូវលទ្ធភាពដើម្បីទទួលបាននូវសេវា ផ្សេងៗ និងការបញ្ចុះតម្លៃដែលផ្តល់ជូនដោយអាជីវកម្ម និងអង្គការ ផ្សេងៗ ។ ហ្វ្លាសខាដ (FLASH Card) ផ្តល់នូវសេវា និងការបញ្ចុះតម្លៃ ដូចគ្នាដែរ សម្រាប់មនុស្សពេញវ័យដែលមានភាពពិការ ។ សេចក្តីតម្រូវនៃលក្ខណៈសម្បត្តិក្នុងការទទួលនេះ មានលក្ខណៈដូចគ្នាទៅនឹងសេចក្តីតម្រូវទាំងឡាយសម្រាប់ប័ណ្ណអនុញ្ញាតសម្រាប់ជិះរថយន្តក្រុង (Metro) ដែលត្រូវមានការកាត់បន្ថយថ្លៃឈ្នួលសម្រាប់មនុស្សពិការ។
ដើម្បីដាក់ពាក្យសុំ សូមទូរស័ព្ទទៅកាន់លេខ (206) 684-0500។

## PeoplePoint : ស្ពានទៅកាន់អត្ថប្រយោជន៍ផ្សេងៗ

សម្រាប់ក្រុមគ្រួសារដែលមានសិទ្ធិទទួលប្រាក់ចំណូល បន្ថែមលើការផ្តល់ជូននូវការបញ្ចុះតម្លៃលើការប្រើប្រាស់ទឹកភ្លើង និងជំនួយបន្ទាន់ ការិយាល័យចៅហ្វាយក្រុងសម្រាប់ពលរដ្ឋវ័យចំណាស់ ផ្តល់នូវលទ្ធភាពងាយស្រួលដើម្បីទទួលនូវអត្ថប្រយោជន៍ផ្សេងៗសម្រាប់ការថែទាំកុមារ ការថែទាំសុខភាព ជំនួយចំណីអាហារ និងក្រេឌីតពន្ធប្រាក់ចំណូលដែលរកបាន ។ ដើម្បីទទួលបានព័ត៌មានបន្ថែម សូមទូរស័ព្ទទៅកាន់លេខ (206) 684-0355 ។